Copy ៤៦ ចុះ ២៤ ១០ ៩ ៣៧

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមការងារថ្នាក់ជាតិ**
**ប្រឆាំងការជួញដូរមនុស្ស**

លេខ......៤២១...... ក.អ.ល.ជ

## របាយការណ៍

## ស្តីពីលទ្ធផល " កិច្ចប្រជុំផែនការរវាងរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាមស្តីពី កិច្ចសហប្រតិបត្តិការលើការអនុវត្តច្បាប់រួមគ្នាប្រឆាំងនឹងការជួញដូរមនុស្ស "

.......

ផ្អែកតាមផែនការសកម្មភាពរួម ដើម្បីអនុវត្តកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាមស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរមនុស្ស និង ជួយដល់ជនរងគ្រោះដោយសារការជួញដូរ ដែលបានប្រារព្ធឡើងនៅទីក្រុងហូជីមិញ កាលពីខែ មករា ឆ្នាំ ២០០៧ ដោយមានការជួយឧបត្ថម្ភពីអង្គការយូនីសេហ្វប្រចាំនៅកម្ពុជា និង អង្គការ យូនីសេហ្វប្រចាំនៅវៀតណាម ចាប់ពីថ្ងៃទី ០៩ ដល់ថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០០៧ នៅសណ្ឋាគារ **សាន់វ៉េ** ។ គណៈប្រតិភូអន្តរក្រសួង និង អង្គការនៃសាធារណរដ្ឋសង្គមនិយមវៀតណាមចំនួន ១១ រូប ដឹកនាំដោយលោក **ខ្វៀន គួកញ៉ាត** អនុប្រធាននាយកដ្ឋានស៊ើបអង្កេតព្រហ្មទណ្ឌ នៃអគ្គនាយកដ្ឋានប៉ូលីស ក្រសួងសន្តិសុខសាធារណៈ បានជួបប្រជុំជាមួយគណៈប្រតិភូអន្តរក្រសួង និង អង្គការនៃព្រះរាជាណាចក្រកម្ពុជាដែលដឹកនាំដោយឯកឧត្តម **អ៊ិត រ៉ាឌី** អនុប្រធានក្រុមការងារថ្នាក់ជាតិ និង ជាអនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ ដើម្បីពិភាក្សាលើផែនការរវាងរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាមស្តីពីកិច្ចសហប្រតិបត្តិការលើការអនុវត្តច្បាប់រួមគ្នាប្រឆាំងនឹងការជួញដូរមនុស្ស ។ អង្គប្រជុំបានប្រារព្ធពិធីបើកក្រោមអធិបតីភាពរបស់លោកជំទាវ **យូ អយ** ប្រធានក្រុមការងារថ្នាក់ជាតិដើម្បីអនុវត្តកិច្ចព្រមព្រៀងអនុស្សរណៈនៃការយោគយល់គ្នា រវាងរាជរដ្ឋាភិបាលកម្ពុជា និងបណ្តាប្រទេសពាក់ព័ន្ធ ដើម្បីលុបបំបាត់អំពើជួញដូរមនុស្ស និងជួយជនរងគ្រោះដោយសារការជួញដូរ និង ជារដ្ឋលេខាធិការ ក្រសួងកិច្ចការនារី ។

កិច្ចប្រជុំមានគោលបំណងគន្លឹះចំនួន ៤ ដូចខាងក្រោម :

១-អគ្គនាយកដ្ឋាននគរបាលនៃក្រសួងសន្តិសុខសាធារណៈវៀតណាម ក្រសួងមហាផ្ទៃ និង ក្រសួងយុត្តិធម៌ ដែលពាក់ព័ន្ធ ក៏ដូចជាដៃគូពាក់ព័ន្ធ ពិភាក្សា និង ព្រមព្រៀងលើវិស័យគន្លឹះសម្រាប់កិច្ចសហប្រតិបត្តិការដើម្បីទប់ស្កាត់ និង ប្រយុទ្ធប្រឆាំងនឹងបទល្មើសជួញដូរមនុស្ស

២-ទីភ្នាក់ងារសំខាន់ៗមកពីភាគីទាំងពីរផ្លាស់ប្តូរព័ត៌មានគ្នា (ច្បាប់ គោលនយោបាយ និង គំរូ) លើការទប់ស្កាត់ ការស៊ើបអង្កេត និង ប្រយុទ្ធប្រឆាំងនឹងការជួញដូរស្ត្រី និង កុមារ

៣-ចែករំលែកគំរូល្អៗអំពីជំនួយផ្នែកច្បាប់ទៅវិញទៅមក

ក្រសួងកិច្ចការនារី ផ្លូវលេខ ៤៧ អតីតកូលាប ១ សង្កាត់ស្រះចក (ភ្នំពេញ) ទូរស័ព្ទ : (៨៥៥) ២៣ ៤២៧ ១២៨ / ទូរសារ : (៨៥៥) ២៣ ៤២៧ ១៣៨
អ៊ីម៉ែល : info@tiptaskforce.org

៤-ក្រសួងយុត្តិធម៌របស់ប្រទេសទាំងពីរ ពិភាក្សាលើអនុសាស៍ ដើម្បីព្រាងកិច្ចព្រមព្រៀងស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមក ។

**I- សកម្មភាព និង ខ្លឹមសារ :**

**ក- បទបង្ហាញ និងការពិភាក្សាក្នុងអង្គប្រជុំធំ :**

ក្នុងរយៈពេលពីរថ្ងៃ អង្គប្រជុំបាន :

- ស្តាប់នូវសេចក្តីសង្ខេបនៃកិច្ចប្រជុំនៅទីក្រុងហូជីមិញនាខែមករា ឆ្នាំ ២០០៧ ដែលផ្តោតលើអនុសាសន៍គន្លឹះ និង សកម្មភាពជាអាទិភាពសម្រាប់ការចោទប្រកាន់ និង ការអនុវត្តច្បាប់ដែលបង្ហាញដោយលោក **ឡេ ទ៉ាន់ដុង** អនុប្រធាន ការិយាល័យប្រចាំការ ១៣០/ជក ក្រសួងសន្តិសុខសាធារណៈវៀតណាម ។

- ស្តាប់នូវយុទ្ធសាស្ត្រសម្រាប់ពង្រឹងកិច្ចសហប្រតិបត្តិការ ក្នុងការអនុវត្តច្បាប់ទ្វេភាគីប្រឆាំងនឹងការជួញដូរមនុស្សដែលបង្ហាញដោយ លោក Willem Pretorium ប្រធានក្រុមនៃគម្រោងតំបន់អាស៊ីទប់ស្កាត់ការជួញដូរមនុស្ស

- ស្តាប់នូវបទពិសោធន៍លើចំណុចជាអាទិភាព លើកិច្ចសហប្រតិបត្តិការក្នុងការអនុវត្តច្បាប់ជាទ្វេភាគីរបស់កម្ពុជា ដែលបង្ហាញដោយលោកស្រីឧត្តមសេនីយ៍ត្រី **អ៊ុន សុគន្ធា** ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និង ការពារអនីតិជន ក្រសួងមហាផ្ទៃ និងបទពិសោធន៍របស់វៀតណាម ដែលបង្ហាញដោយលោក **ផាម ទ៉ាន់ហ៊ុង** អនុប្រធាននាយកដ្ឋាននគរបាលព្រហ្មទណ្ឌ នៃអគ្គនាយកដ្ឋាននគរបាលវៀតណាម និងពិភាក្សាក្នុងអង្គប្រជុំទាំងមូល ។

- ស្តាប់នូវបទពិសោធន៍អំពីជំនួយផ្នែកច្បាប់កម្ពុជាដែលបង្ហាញដោយឯកឧត្តម **អ៊ិត រ៉ាឌី** អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ និង បទពិសោធន៍របស់វៀតណាម ដែលបង្ហាញដោយលោក **ឡេវ៉ង ក្វុងហុង** តំណាងក្រសួងយុត្តិធម៌វៀតណាម និងពិភាក្សាក្នុងអង្គប្រជុំទាំងមូល ។

- ស្តាប់នូវបទពិសោធន៍ថ្នាក់តំបន់ និង គំរូល្អៗនៃជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុង និង ក្រៅតំបន់ ដែលបង្ហាញ ដោយលោកWillem Pretorium ប្រធានក្រុមនៃគម្រោងតំបន់អាស៊ីទប់ស្កាត់ការជួញដូរមនុស្ស ។

**ខ- ការពិភាក្សាជាពីរក្រុមតូចដើម្បីកំណត់វិស័យនៃកិច្ចសហប្រតិបត្តិការទ្វេភាគី/រួមគ្នា :**

- <u>ក្រុមទីមួយ</u> : ដឹកនាំដោយក្រសួងមហាផ្ទៃកម្ពុជា និង អគ្គនាយកដ្ឋាននគរបាលវៀតណាម ពិភាក្សា និង អនុម័តលើការអនុវត្តច្បាប់ដែលក្នុងនោះបានលំអិតលើ ការពង្រឹងកិច្ចសហប្រតិបត្តិការថ្នាក់កណ្តាល និង តំបន់ព្រំដែន / ថ្នាក់មូលដ្ឋាន-ការពង្រឹងយន្តការផ្លាស់ប្តូរព័ត៌មាន-ការប្រមូល និង ចែករំលែកព័ត៌មានចារកម្ម-សំណើប្រតិបត្តិការរួមប្រឆាំងការជួញដូរមនុស្ស និង ការសង្គ្រោះជនរងគ្រោះ និង កិច្ចការពារជនរងគ្រោះ (លទ្ធផលនៃការពិភាក្សាលំអិតមានជូនភ្ជាប់ជាមួយ) ។

- <u>ក្រុមទីពីរ</u> : ដឹកនាំដោយក្រសួងយុត្តិធម៌កម្ពុជា និង ក្រសួងយុត្តិធម៌វៀតណាម ពិភាក្សា និង អនុម័តលើជំនួយផ្នែកច្បាប់ទៅវិញទៅមក និង ការធ្វើបត្យាប័នដែលក្នុងនោះ បានលំអិតលើយុទ្ធសាស្ត្រដើម្បីជម្រុញកិច្ចព្រមព្រៀងជំនួយផ្នែកច្បាប់ទៅវិញទៅមក និង ការធ្វើបត្យាប័ន-វិសាលភាព និង ខ្លឹមសារ និង ជំហានបន្ទាប់ (លទ្ធផលនៃការពិភាក្សាលំអិតមានជូនភ្ជាប់ជាមួយ) ។

**II- លទ្ធផលនៃកិច្ចប្រជុំ :**

**II- លទ្ធផលនៃកិច្ចប្រជុំ :**

តាមរយៈនៃកិច្ចប្រជុំរយៈពេលពីរថ្ងៃនេះ គណៈប្រតិភូទាំងពីរប្រទេសបានយកចិត្តទុកដាក់ពិភាក្សាស៊ីជម្រៅលើប្រធានបទនីមួយៗ ហើយសម្រេចបានលទ្ធផលគួរជាទីមោទនៈ ។ នៅក្នុងពិធីបិទកិច្ចប្រជុំ លោក Nguyen Quoc Nhat ប្រធានគណៈប្រតិភូវៀតណាម បានសម្តែងនូវការអបអរសាទរយ៉ាងខ្លាំងចំពោះលទ្ធផលដែលប្រកបដោយជោគជ័យរបស់អង្គប្រជុំ និង ថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជាដែលបានរៀបចំអោយមានកិច្ចប្រជុំនេះឡើង និង កិច្ចគាំទ្ររបស់អង្គការដៃគូ ។ ជាមួយនេះដែរ លោកបានបញ្ជាក់ដោយសង្កត់ធ្ងន់ថា : តាមរយៈកិច្ចប្រជុំនេះ គណៈប្រតិភូទាំងពីរប្រទេសបានយល់គ្នាកាន់តែច្រើន និង កាន់តែជ្រាលជ្រៅឡើង ហើយក្នុងរយៈពេលដ៏ខ្លីខាងមុខនេះ កិច្ចសហប្រតិបត្តិការទាំងពីរប្រទេសនឹងបានកាន់តែប្រសើរឡើងថែមទៀត ។

ឆ្លើយតបទៅនឹងមតិលោក **ឡេង គួកញ៉ាត** ឯកឧត្តម **ម៉ាន់ ណយ** ប្រធាននាយកដ្ឋានកណ្តាល សន្តិសុខ ក្រសួងមហាផ្ទៃបានឯកភាពទាំងស្រុង និង ជឿជាក់ថា ក្រុមការងារទ្វេភាគីទទួលបាននូវបទពិសោធន៍ល្អៗកាន់តែច្រើនឡើងថែមទៀត ក្នុងការអនុវត្តការងាររួមគ្នាដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ។ ឯកឧត្តមក៏បានសង្កត់ធ្ងន់ផងដែរថា : នាយកដ្ឋាននៃប្រទេសទាំងពីរ ជាពិសេសនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និង ការពារអនីតិជន ក្រសួងមហាផ្ទៃ ត្រូវតែបង្កើនកិច្ចសហប្រតិបត្តិការខ្ពស់ ដើម្បីឈានទៅសម្រេចជោគជ័យនូវចំណុចទាំង ៥ ដែលបានអនុម័តរួចលើផ្នែកអនុវត្តច្បាប់ ក្នុងការលុបបំបាត់អំពើជួញដូរមនុស្ស ។ ជាមួយនេះដែរ ទាក់ទងដល់ផ្នែកជំនួយផ្នែកច្បាប់ទៅវិញទៅមក និង ការធ្វើបត្យាប័នដែលមាន ៣ ចំណុច ឯកឧត្តមបានបញ្ជាក់ច្បាស់ថា កន្លងមក ទោះបីជាយើងមិនទាន់មានសន្ធិសញ្ញាស្តីពីបត្យាប័នក៏ដោយ ក៏យើងបានអនុវត្តដោយជោគជ័យដែរ ហើយឯកឧត្តមបានសង្ឃឹមយ៉ាងមុតមាំថា លទ្ធផលនៃកិច្ចប្រជុំពិភាក្សាក្នុងរយៈពេលពីរថ្ងៃនេះ នឹងធ្វើអោយការអនុវត្តកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាមស្តីពី កិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរស្ត្រី និង កុមារ និង ជួយដល់ជនរងគ្រោះដោយសារការជួញដូរ បានសម្រេចជោគជ័យក្នុងពេលអនាគតដ៏ឆាប់ខាងមុខ និង សង្ឃឹមលើកិច្ចសហប្រតិបត្តិការ និង ការគាំទ្រពីអង្គការជាដៃគូអភិវឌ្ឍន៍នានា ជាពិសេស អង្គការយូនីសេហ្វដែលបានជួយឧបត្ថម្ភគាំទ្រអោយមានកិច្ចប្រជុំនេះឡើង ។

អង្គប្រជុំបានបញ្ចប់នៅម៉ោង ១៧:០០ ល្ងាចថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៧ ក្រោមបរិយាកាសរីករាយ ស្និទ្ធស្នាល និង ប្រកបដោយលទ្ធផលដ៏មានផ្លែផ្កា ។

នៅព្រឹកថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៧ គណៈប្រតិភូសាធារណរដ្ឋសងមនិយមវៀតណាម បានធ្វើទស្សនកិច្ចនៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និង ការពារអនីតិជន ក្រសួងមហាផ្ទៃ ក្នុងនោះបានស្វែងយល់ពីរចនាសម្ព័ន្ធតួនាទី និង ភារកិច្ចរបស់នាយកដ្ឋាន ។

**<u>សំណូមពរ</u>**

- ស្នើសុំគោលការណ៍ ឯកឧត្តមអគ្គស្នងការនគរបាលជាតិ ជួបប្រជុំនៅដើមខែ តុលា ឆ្នាំ ២០០៧ រវាងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និង ការពារអនីតិជន និង ការិយាល័យជំនាញខេត្តនៅតាមបណ្តោយព្រំដែនកម្ពុជា

និង ការិយាល័យប្រឆាំងការជួញដូរមនុស្សវៀតណាម ជួបពិភាក្សាស្តីពី បទល្មើសជួញដូរមនុស្សឆ្លងដែនក្នុងខេត្តតៃនិញ ប្រទេសវៀតណាម ។

- ភាគីវៀតណាមសំណូមពរមកនគរបាលកម្ពុជា ធ្វើផែនការសហប្រតិបត្តិការជាក់ស្តែង ដើម្បីទប់ស្កាត់បទល្មើសជួញដូរមនុស្សឆ្លងដែន តាមបណ្តាខេត្តជាប់ព្រំដែន ។
- សុំគោលការណ៍ផ្លាស់ប្តូរព័ត៌មានជនល្មើស ជនរងគ្រោះ ស្តីពីបទល្មើសឆ្លងដែន ។
- សុំគោលការណ៍ជួបប្រជុំបូកសរុបលទ្ធផល របស់ជំនាញប្រឆាំងការជួញដូរមនុស្សឆ្លងដែន រយៈពេល ០៣ ខែ ទៅ ០៦ ខែ និង ០១ ឆ្នាំ រវាងនគរបាលជំនាញនៃប្រទេសទាំងពីរជាប់ព្រំដែនកម្ពុជា វៀតណាម ។

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ៥ ឆ្នាំ ២០០៧

អ្នកធ្វើរបាយការណ៍

Rady

ឯកឧត្តម **អ៊ិត រ៉ាឌី**

អនុប្រធានក្រុមការងារថ្នាក់ជាតិ

និងជា អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌

បានពិនិត្យ និង ឯកភាព

លោកជំទាវ យូ អយ

ប្រធានក្រុមការងារថ្នាក់ជាតិ

និងជា រដ្ឋលេខាធិការក្រសួងកិច្ចការនារី